# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

លេខ......៧៨៤/.........សកភព-កស /២០២៣

# សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រអភិរក្សជីវចម្រុះ ជំនាន់ទី១៩ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញសម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤

**យោង៖** ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ១៣៥៩អយក.ប្រក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រអភិរក្សជីវចម្រុះ។

ដោយមានកិច្ចសហការជាមួយនឹង Swedish International Development Agency (SIDA) នៃប្រទេសស៊ុយអែត សាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងរៀបចំការប្រឡងជ្រើសរើសនិស្សិតចំនួន២០-៣០នាក់ ដើម្បីចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រអភិរក្សជីវចម្រុះជំនាន់ទី១៩ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤។ កម្មវិធីនេះ ត្រូវសិក្សាជាមួយសាស្ត្រាចារ្យខ្មែរ និងបរទេស។

**លក្ខខណ្ឌជ្រើសរើស៖**
- ត្រូវចេះភាសាអង់គ្លេសជ្រៅជ្រះ
- ត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាផ្នែកវិទ្យាសាស្ត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- ត្រូវមានបទពិសោធន៍ការងារដែលទាក់ទងនិងផ្នែកជីវចម្រុះយ៉ាងហោចណាស់រយៈពេលមួយឆ្នាំ

**សំណុំលិខិត៖**
- ពាក្យសុំចុះឈ្មោះចូលរៀនត្រៀម ចំនួន ០១ច្បាប់
- សញ្ញាបត្រថ្នាក់បរិញ្ញាដែលបញ្ជាក់ពីគ្រឹះស្ថានសិក្សា ខណ្ឌ ឬស្រុក ចំនួន ០១ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (សម្រាប់អ្នកដែលមានការងារធ្វើ) ចំនួន ០១ច្បាប់
- រូបថតថ្មី (ផ្ទៃពណ៌ខៀវ) ទំហំ ៤ x ៦ ថតចំពីមុខ ចំនួន ០៣សន្លឹក
- រូបថតថ្មី (ផ្ទៃពណ៌ខៀវ) ទំហំ ៣ x ៤ ថតចំពីមុខ ចំនួន ០២សន្លឹក

**ទទួលពាក្យ៖**
- ចាប់ពីថ្ងៃផ្សាយដំណឹងទៅដល់ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

**សម័យប្រឡង៖** ថ្ងៃចន្ទ ២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣

**វិញ្ញាសាប្រឡង៖** មានបីទម្រង់គឺ សម្ភាសន៍ អាន និងសរសេរ។ ការប្រឡងទាំងបីទម្រង់នេះនឹងត្រូវធ្វើជាភាសាអង់គ្លេស ដោយផ្តោតលើបរិបទជីវចម្រុះ អេកូឡូស៊ី និងបរិស្ថាន។

**ទីកន្លែងទទួលពាក្យ៖** បន្ទប់លេខ៤១៥ ជាន់ទី៤ អាគារ A សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (មណ្ឌល១)

**ទូរស័ព្ទទំនាក់ទំនង៖** (855)**071 227 2702 / 088 406 6318** (Telegram) ឬអ៊ីម៉ែល៖ **mbiodiversity.info@rupp.edu.kh**

ថ្ងៃ ... ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២៣

**សាកលវិទ្យាធិការ**

**ជ.សាកលវិទ្យាធិការ**

**ឃិត ដែស**